# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ:** ០០២/១៤-០៨-២០០៦

**ឈ្មោះរឿងក្តី:** **កាំង ហ្គេកអ៊ាវ**

**ដំកល់រឿងនៅ:** អង្គបុរេជំនុំជម្រះ

**ថ្ងៃចុះបញ្ជី:** ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧

**ចុះបញ្ជីដោយ:** មេធាវីការពារក្តី

**ភាសា:** បារាំង(ជាភាសាដើម)
ខ្មែរ(បកប្រែក្រៅផ្លូវការ លើកលែងតែមានការបកប្រែ
ជាផ្លូវការដោយអ្នកបកប្រែរបស់ផ្នែកគ្រប់គ្រងតុលាការ)

**ប្រភេទឯកសារ:** សំងាត់

---

**សារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាសំរេចឃុំខ្លួនជាបណ្តោះអាសន្ន**
**ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧**

---

<u>សំរាប់:</u>

លោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**
កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅប្រទេស
កម្ពុជា សញ្ជាតិកម្ពុជា មុខរបរគ្រូបង្រៀន
បច្ចុប្បន្ន កំពុងត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំង
របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

<u>ដោយមានមេធាវីការពារក្តី:</u>

លោក **ការ សាវុត្ថ**

លោក Francois Roux

<u>ជំនួយការ:</u>

កញ្ញា Heleyn Unac

លោក **ចាន់ រ៉ាវុធ**

<u>ដោយមានវត្តមានរបស់:</u>

**សហព្រះរាជអាជ្ញា**

លោកស្រី **ជា លាង**

លោក **រ៉ូប៊ែរ ប៉ឺទី**

# ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. អង្គហេតុ និងនីតិវិធី

1. ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ លោក **កាំង ហ្គេកអ៊ាវ** ត្រូវបានចាប់ខ្លួនដោយអាជ្ញាធររបស់ព្រះរាជាណាចក្រកម្ពុជា។

2. ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ចៅក្រមស៊ើបអង្កេតនៅតុលាការយោធាបានធ្វើការស៊ើបអង្កេតលើរឿងក្ដីរបស់លោក **កាំង ហ្គេកអ៊ាវ** ជាបន្តបន្ទាប់ចំពោះទង្វើដែលគាត់បានប្រព្រឹត្តទៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលជាអតីតប្រធានមន្ទីរ ស-២១។ លោក **កាំង ហ្គេកអ៊ាវ** ត្រូវបានចោទប្រកាន់ជាបន្តបន្ទាប់អំពីបទឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខជាតិ (១០ ឧសភា ១៩៩៩[1]) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[2] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២២ កុម្ភៈ ២០០២[3]) និងចុងក្រោយពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មទៅលើអ្នក ដែលទទួលបានការការពារជាអន្តរជាតិ (២៨ កុម្ភៈ ២០០៥[4])។

3. ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០២មក ការចោទប្រកាន់ និងដីកាសំរេចឃុំខ្លួន និងបន្តឃុំខ្លួន លោក **កាំង ហ្គេកអ៊ាវ** បានធ្វើឡើងដោយផ្អែកយ៉ាងច្បាស់លាស់ទៅលើ ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១។ ជាពិសេស វាផ្អែកទៅលើ:
   - មាត្រា ៥ និង៣៩ នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5]។
   - មាត្រា ៦ និង៨ នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ[6]។

---

[1] សូមមើលដីកាបញ្ជូនរឿងអោយស៊ើបសួររបស់អយ្យការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។

[2] សូមមើលដីកាបញ្ជូនរឿងអោយស៊ើបសួររបស់អយ្យការយោធា ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩។

[3] សូមមើលដីកាសំរេចឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០២។

[4] សូមមើលដីកាសំរេចឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥។

[5] សូមមើលដីកាសំរេចឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០២ ២០០៣ និង២០០៤។

[6] សូមមើលដីកាសំរេចឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ២០០៦ និង២០០៧។

4. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញដីកាបង្គាប់ឱ្យនាំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ហើយដែលគាត់ត្រូវបានផ្ទេរពីមន្ទីរឃុំឃាំងរបស់តុលាការយោធាទៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ។

5. ក្នុងអំឡុងពេលនេះ ដោយគិតទាំងថ្ងៃត្រូវចាប់ខ្លួន នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២១៩៩៩ រហូតដល់ថ្ងៃដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ លោក **កាំង ហ្គេកអ៊ាវ** ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ន ដោយតុលាការយោធាក្រុងភ្នំពេញ អស់រយៈពេលជាសរុបចំនួន៨ឆ្នាំ ២ខែ និង២០ថ្ងៃ។

6. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកការស៊ើបអង្កេតលើរឿងក្ដីលោក **កាំង ហ្គេកអ៊ាវ**ជាថ្មីម្ដងទៀត *"ចំពោះការដែលគាត់បានគ្រប់គ្រងលើមន្ទីរសន្តិសុខ ស-២១ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ជាកន្លែងដែលការរំលោភបំពានឥតគណនាត្រូវបានប្រព្រឹត្ត នៅក្រោមអំណាចរបស់ខ្លួនប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល (ការឃុំឃាំងដោយបំពាន ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដ៏ទៃទៀត ការសំលាប់រង្គាល។ល។) ដែលស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តនយោបាយ ជាលក្ខណៈប្រព័ន្ធ ឬមានលក្ខណៈទូទៅ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានបញ្ញត្តិ និងដាក់ទោស ក្នុងមាត្រា ៥ ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤"*។

7. សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញដីកាសំរេចឃុំខ្លួនបណ្ដោះអាសន្នលើលោក **កាំង ហ្គេកអ៊ាវ** ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សំរាប់រយៈពេលអតិបរមា១ឆ្នាំ។

8. មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ចំពោះដីកាសំរេចឃុំខ្លួនជាបណ្ដោះអាសន្នខាងលើនេះ នៅការិយាល័យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ហើយសូមផ្ដល់អំណះអំណាងដូចខាងក្រោមនេះ ដើម្បីជាការសំអាងលើបណ្ដឹងឧទ្ធរណ៍នេះ។

9. ជាបឋម មេធាវីការពារក្ដីសំណូមពរអង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យសវនាការនៃការពិភាក្សាដេញដោលតទល់គ្នាអំពីបណ្ដឹងឧទ្ធរណ៍នេះធ្វើឡើងជាសាធារណៈ ដោយអនុវត្តតាមវិធាន ៧៧(៦) នៃវិធានផ្ទៃក្នុង។

10. មេធាវីការពារក្ដីសូមអះអាងថា វិធានការណ៍នេះគឺធ្វើឡើងដើម្បីជាប្រយោជន៍ដល់រដ្ឋបាលយុត្តិធម៌ ហើយវាក៏មិនប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈអ្វីដែរ។

## II. <u>អំណះអំណាងក្នុងការការពារក្ដី</u>

11. មេធាវីការពារក្ដីសំណូមពរអោយបដិសេធដីកាសំរេចចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ខាងលើនេះ ព្រមទាំងដោះលែងលោក **កាំង ហ្គេកអ៊ាវ**អោយមានសេរីភាពជាបន្ទាន់ ដោយហេតុថាការឃុំខ្លួនជាបណ្ដោះអាសន្ន ដែលបានធ្វើឡើងចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩មកនេះ បានរំលោភច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកសិទ្ធិមនុស្ស ម្យ៉ាងទៀតសហចៅក្រមស៊ើបអង្កេតពុំបានពិចារណាពីផលវិបាកគតិយុត្តិដែលបណ្ដាលមកពីការរំលោភច្បាប់នេះឡើយ។ (ក)

12. ដោយឡែក មេធាវីការពារក្ដីយល់ថាសហចៅក្រមស៊ើបអង្កេតត្រូវគិតអំពីថិរវេលាឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ**អស់ពេល៨ឆ្នាំកន្លងមកនេះ ដោយហេតុថាចៅក្រមត្រូវសំរេចអំពីឱកាសថា តើគួរឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** សំរាប់រយៈពេលមួយឆ្នាំបន្តទៀតឬអត់ ហើយថាល័ក្ខខ័ណ្ឌដើម្បីឃុំខ្លួនគាត់ដែលបានកំណត់ក្នុងដីកាសំរេចចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ មិនត្រូវបានបំពេញនៅឡើយទេ។ អាស្រ័យដូចបានជំរាបពីហេតុផលខាងលើនេះ មេធាវីការពារក្ដីសូមសំណូមពរអោយលោកសហចៅក្រមដោះលែងលោក **កាំង** ហ្គេកអ៊ាវឲមានសេរីភាព។ (ខ)

13. ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីសុំអោយមានការជួសជុលព្យសនកម្មដល់លោក **កាំង ហ្គេកអ៊ាវ** ពីការឃុំខ្លួនគាត់ហួសពីរយៈពេលដែលច្បាប់បានកំណត់។ (គ)

## ក អំពីអនីត្យានុកូលភាពនៃការឃុំខ្លួនជាបណ្ដោះអាសន្នលោក កាំង ហ្គេកអ៊ាវ និងផលវិបាករបស់វា

14. មេធាវីការពារក្ដីសូមអោយអង្គបុរេជំនុំជម្រះពិចារណា អំពីការដែលសហចៅក្រមស៊ើបអង្កេតមិនបានឆ្លើយតបទៅនឹងអំណះអំណាងដែលមេធាវីការពារក្ដីបានលើកឡើង អំពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលោក **កាំង ហ្គេកអ៊ាវ** ដោយលើសការកំណត់របស់ច្បាប់នេះ។

15. នៅក្នុងការតទល់គ្នា មេធាវីការពារក្ដីបានលើកឡើងថា លោក **កាំង ហ្គេកអ៊ាវ** ត្រូវបានឃុំខ្លួនអស់រយៈពេលជាង៨ឆ្នាំមកហើយ ដែលនេះជាការរំលោភលើច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស។

16. ជាពិសេសទៅទៀត មេធាវីការពារក្ដីបានលើកឡើងពីការរំលោភលើមាត្រា ១៤(៣-គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ដែលមានបទបញ្ញត្តិស្រដៀងគ្នាទៅនឹងបទបញ្ញត្តិក្នុងមាត្រា ៩(៣) នៃកតិកាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ) ដែលក្នុងនោះបានចែងអំពីគោលការណ៍គ្រឹះមួយថា ជនត្រូវចោទទាំងអស់ត្រូវទទួលបានជំនុំជម្រះក្នុងចិរវេលាសមស្រប ឬដោះលែង។

17. មេធាវីការពារក្ដីសូមនិយាយឡើងវិញ អំពីអំណះអំណាងដែលមេធាវីការពារក្ដីបានលើកឡើងនៅមុខសហចៅក្រមស៊ើបអង្កេត ដែលថាការឃុំខ្លួនបណ្ដោះអាសន្នលោក **កាំង ហ្គេកអ៊ាវ**នេះ ផ្ទុយនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស។ (១)

18. មេធាវីការពារក្ដីសូមនិយាយថា ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានសមត្ថកិច្ច ក្នុងការពិចារណានូវផលវិបាកគតិយុត្តិ ដែលបណ្ដាលមកពីការរំលោភបំពានលើច្បាប់នេះ។ (២)

19. មេធាវីការពារក្ដីយល់ឃើញថាមានតែការដោះលែងលោក **កាំង ហ្គេកអ៊ាវ**ឱ្យមានសេរីភាពតែប៉ុណ្ណោះ ទើបអាចដោះស្រាយបញ្ហាមួយចំណែកអំពីការរំលោភសិទ្ធិរបស់គាត់បាន។ (៣)

**(១) ការឃុំខ្លួនបណ្ដោះអាសន្នលោក កាំង ហ្គេកអ៊ាវ ខុសនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស**

20. មេធាវីការពារក្ដីសូមអះអាងថាការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** បានរំលោភលើសិទ្ធិរបស់គាត់ជាជនជាប់ចោទ ដែលត្រូវទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលដ៏សមស្របមួយ ឬដោះលែងដោយអនុលោមតាមច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស។

ក <u>ច្បាប់កម្ពុជា:</u>

21. បទបញ្ញត្តិច្បាប់ស្ដីពីការឃុំខ្លួនជាបណ្ដោះអាសន្នដែលត្រូវយកមកអនុវត្តក្នុងរឿងនេះមានដូចជា: រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ និងច្បាប់ស្ដីពីរយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩ ។

22. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីគោលការណ៍គ្រឹះជាច្រើន ដែលក្នុងនោះបានកំណត់ថា៖ “ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន” (មាត្រា ៣២) ហើយ “ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងធ្វើទៅកើតលុះត្រាតែអនុវត្តន៍ត្រឹមត្រូវតាមបញ្ញត្តិច្បាប់” (មាត្រា ៣៨) ។

23. ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ជាច្បាប់ដែលបានយកមកអនុវត្តក្នុងពេលចាប់ខ្លួន លោក **កាំង ហ្គេកអ៊ាវ** កាលពីខែឧសភា ឆ្នាំ១៩៩៩ ហើយនៅក្នុងមាត្រា ២១(១) បានចែងថា៖ គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលជំនុំជម្រះយ៉ាងយូរបំផុត៦ខែ ក្រោយពីថ្ងៃចាប់ខ្លួន។

24. នាខែសីហា ឆ្នាំ១៩៩៩ ច្បាប់ស្តីពីការឃុំខ្លួនជាបណ្តោះអាសន្នត្រូវបានប្រកាសអោយប្រើ។ មាត្រា ១ នៃច្បាប់នេះបានចែងថា ការឃុំខ្លួនជនត្រូវចោទពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ មិនត្រូវមានរយៈពេលលើសពី៣ឆ្នាំនោះឡើយ។

25. លោក **កាំង ហ្គេកអ៊ាវ**ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នដោយយោងលើច្បាប់នេះ ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៩៩រហូតមក។ នៅកាលបរិច្ឆេទនេះ លោក **កាំង ហ្គេកអ៊ាវ**ត្រូវបានចោទប្រកាន់ និងសំរេចឲឃុំខ្លួនអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៏។

26. ប្រសិនបើអនុវត្តតាមច្បាប់នេះ លោក **កាំង ហ្គេកអ៊ាវ** គួរតែទទួលបានជំនុំជម្រះក្នុងអំឡុងពេលអតិបរមា ៣ឆ្នាំ ឬក៏ដោះលែងអោយមានសេរីភាព។

27. ក៏ប៉ុន្តែ បើពិនិត្យលើសំណុំរឿងស៊ើបអង្កេតរបស់តុលាការយោធា យើងឃើញថារូបគាត់ត្រូវបានចោទប្រកាន់ពីបទល្មើសថ្មីៗទៀតនៅខែកុម្ភៈ ឆ្នាំ២០០២។ ដូច្នេះ គាត់ត្រូវបានបន្តឃុំខ្លួនបណ្តោះអាសន្ន សំរាប់រយៈពេល៣ឆ្នាំជាបន្ថែមទៀត។ ចាប់ពីពេលនោះមក លោក **កាំង ហ្គេកអ៊ាវ** ក៏ត្រូវបានចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងលើមាត្រា៥ និង៣៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។

28. បន្ទាប់មកទៀត ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ បទចោទថ្មីៗត្រូវបានគេលើកមកចោទសារជាថ្មីទៀត ដោយក្នុងនោះមានទាំងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មទៅលើអ្នកទទួលបានការការពារជាអន្តរជាតិ ហើយរូបគាត់ក៏ត្រូវបានគេបន្តឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់តុលាការយោធាក្រុងភ្នំពេញ រហូតដល់គាត់ត្រូវបានផ្ទេរមកមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

29. ពេលបានមើលឯកសារស៊ើបអង្កេត និងជាពិសេស ដីកាសំរេចឃុំខ្លួនបណ្តោះអាសន្ន របស់តុលាការយោធាមក យើងពុំមានមន្ទិលអ្វីដែលថាការដែលបានចោទប្រកាន់ទៅលើលោក **កាំង ហ្គេកអ៊ាវ** ពីបទល្មើសថ្មីៗនេះ គឺមិនមែនដោយសារតែមានហេតុការណ៍ថ្មីៗបានលេចឡើង ដែលធ្វើអោយ

ចៅក្រមត្រូវចេញដីកាបង្គាប់ឲឃុំខ្លួនគាត់នោះឡើយ ប៉ុន្តែគឺគ្រាន់តែដើម្បីអោយមានការបន្តឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** អោយលើសពីរយៈពេល៣ឆ្នាំដែលច្បាប់បានកំណត់តែប៉ុណ្ណោះ។

30. តាមរយៈទង្វើនេះ តុលាការយោធាក្រុងភ្នំពេញពុំបានអនុវត្តតាមច្បាប់ទេ ប៉ុន្តែផ្ទុយទៅវិញ ដើម្បីសំរេចបំណងនេះ គេគ្រាន់តែធ្វើការពង្វាង ដើម្បីអាចបន្តឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** សំរាប់រយៈពេលមិនកំណត់តែប៉ុណ្ណោះ។

31. ដូច្នេះគឺមានតែតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដែលអាចកំណត់បានថា ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០២មក សិទ្ធិរបស់លោក **កាំង ហ្គេកអ៊ាវ** ក្នុងការទទួលបានជំនុំជម្រះក្នុងរយៈពេល៣ឆ្នាំទៅតាមការកំណត់ក្នុងច្បាប់នេះ ត្រូវបានរំលោភបំពាន។

32. ចាប់តាំងពីកាលបរិច្ឆេទនេះមក ការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** បានហួសរយៈពេលអតិបរមា៣ឆ្នាំដែលបានចែងនៅក្នុងច្បាប់ស្តីពីរយៈពេលការឃុំខ្លួនណ្តោះអាសន្នឆ្នាំ១៩៩៩។

33. ដោយហេតុថាការសំរេចឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ជាបណ្តោះអាសន្នមិនត្រូវបានធ្វើអោយបានត្រឹមត្រូវតាមច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រា៣៨ ៃនរដ្ឋធម្មនុញ្ញ ដូចនេះ ចាប់ពីខែកញ្ញា ឆ្នាំ២០០២មក ការឃុំខ្លួននេះត្រូវមានលក្ខណៈខុសច្បាប់ ហើយលោក**កាំង ហ្គេកអ៊ាវ** គួរតែត្រូវបានដោះលែងចាប់ពីថ្ងៃនេះតទៅដែរ។

34. ដោយឡែក មេធាវីការពារក្តីសូមលើកឡើងថា ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលបានចូលជាធរមានកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៧ និងដែលមានអានុភាពអនុវត្តលើរឿងក្តីនេះចាប់ពីកាលបរិច្ឆេទនេះផងដែរនោះ[7] មាត្រា ២០៣ នៃក្រមនេះបានរំលឹកឡើងវិញនូវគោលការណ៍ដែលថា តាមច្បាប់កម្ពុជា ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនជាករណីពិសេស[8]។

35. ដោយឡែក មាត្រា ២១០ នៃក្រមនេះបានចែងថា ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្ន

---

[7] មាត្រា ៦០៨ នៃក្រមនេះចែងថា៖ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះរឿងក្តីកំពុងចាត់ការ គឺជារយៈពេលដែលមានចែងនៅក្នុងច្បាប់ចាស់ លើកលែងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម។

[8] មាត្រា២០៣នៃក្រមនេះ (គោលការណ៍នៃការឃុំខ្លួនជាបណ្តោះអាសន្ន) ចែងថា៖ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនជាបណ្តោះអាសន្ន នៅក្នុងល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។

មិនអាចលើសពី១ឆ្នាំបានទេ។ ថិរវេលានេះអាចពន្យារបានតែ២ដងគត់ ក្រមនេះបានកំណត់ថាការឃុំខ្លួនបណ្តោះអាសន្ននេះអាចបង្គាប់ឲពន្យារបានចំពោះបទល្មើសនេះតែថិរវេលា៣ឆ្នាំជាអតិបរមា[9]។

36. ដូច្នេះ បទបញ្ញត្តិនេះបញ្ជាក់ឡើងវិញនូវគោលការណ៍ដែលថា ការឃុំខ្លួនបណ្តោះអាសន្នដែលមានរយៈពេលលើសពី៣ឆ្នាំ ត្រូវខុសនឹងច្បាប់កម្ពុជា។

37. បើពិនិត្យលើបទបញ្ញត្តិច្បាប់ទាំងអស់នេះ យើងឃើញថា តាមច្បាប់កម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នដែលមានរយៈពេលជាង៨ឆ្នាំ វាពិតជាមានលក្ខណៈហួសកំរិត និងខុសច្បាប់។

ខ <u>ច្បាប់អន្តរជាតិៈ</u>

38. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ចែងថា៖ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស សិទ្ធិនារី និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

39. បើអនុវត្តន៍តាមបទបញ្ញត្តិនៃមាត្រានេះ អាជ្ញាធរផ្នែកយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទបញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស ដូចជា កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ(PIDCP) ឆ្នាំ១៩៦៦ជាដើម។

40. ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីសំរេចមួយ កាលពីថ្ងៃទី១០ ខែកក្កដា ២០០៧នេះដោយអះអាងសារជាថ្មីថា៖ ចៅក្រមកម្ពុជាទាំងអស់ត្រូវតែគោរពតាមបទបញ្ញត្តិទាំងអស់នោះ[10]។

41. មេធាវីការពារក្តីសូមរំលឹកថាព្រះរាជាណាចក្រកម្ពុជាបានធ្វើបត្យាប័ន លើកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ នៅថ្ងៃទី២៦ ឧសភា ១៩៩២ ហើយកតិកាសញ្ញានេះបានចូលជាធរមានចាប់ពីកាលបរិច្ឆេទនោះមក។

---

[9]មាត្រា ២១០ នៃក្រមនេះ(រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)ចែងថា៖ ក្នុងករណីដែលមានការចោទប្រកាន់ពី បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី១ឆ្នាំបានទេ ចំពោះបទល្មើសនិមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបានមួយឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲពន្យារការឃុំខ្លួនបណ្តោះអាសន្ន បានតែ២ដងគត់។

[10] តាមពិត ក្នុងរឿងនោះវាជាការអនុវត្តនូវអនុសញ្ញាស្តីពីសិទ្ធិកុមារ។

42. ជាវិបាក ចាប់តាំងពីថ្ងៃត្រូវចាប់ខ្លួនមក លោក **កាំង ហ្កេកអ៊ាវ** ត្រូវតែទទួលបាននូវការការពារដោយកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលផ្តល់ការការពារដល់បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសផ្សេងៗ។

43. ជាពិសេស អាជ្ញាធរយុត្តិធម៌ដែកម្ពុជាលមានសមត្ថកិច្ចលើរឿងក្តីនេះ ត្រូវតែគោរពតាមមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិនេះ។

44. ដូចគ្នាដែរ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ត្រូវគោរពតាមបទបញ្ញត្តិនេះដែរ[11]។

45. មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ ចែងថា៖

*គ្រប់បុគ្គលទាំងអស់ដែលត្រូវបានឃាត់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌណាមួយ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់អោយបំពេញមុខងារតុលាការ ក្នុងកំឡុងពេលយ៉ាងខ្លីបំផុត <u>និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង</u>។ ការឃុំខ្លួនបុគ្គលដើម្បីរង់ចាំការជំនុំជម្រះមិនមែនជាវិធានទូទៅទេ តែការឲនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅថ្ងៃសវនាការ ឬនៅក្នុងដំណាក់កាលដ៏ទៃទៀតនៃនីតិវិធីវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម*[12]។

46. នៅក្នុងការពន្យល់អធិប្បាយជាទូទៅមួយលើមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិនេះ គណៈកម្មាធិការសិទ្ធិមនុស្សបាន រំលឹកអំពីគោលការណ៍ដែលថា ការឃុំខ្លួនបណ្តោះអាសន្នគួរតែជាអញ្ញត្រកម្ម ហើយគួរមានរយៈពេលខ្លីបំផុតដែលអាចទៅរួច[13]។

47. គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់អំពីចំណុចនេះនៅក្នុងរឿងក្តីរវាង Sandy Sextus តទល់នឹង Trinidad និងTrobago[14] ថា៖ *<u>"ដូចតាមការអះអាងអំពីការពន្យារពេលក្នុងដំណាក់កាលបុរេជំនុំ</u>*

---

[11] ដោយឡែក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ត្រូវអនុវត្តតាមមាត្រា ១៤(៣-គ) នៃកតិកាសញ្ញាអន្តរជាតិនេះដែរ ដែលធានានូវសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្នុងថិរវេលាសមស្រប។ សូមមើលមាត្រា ៣៣និង៣៥ ថ្មី ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ និងមាត្រា១២ និង១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលយោងលើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ។ ដូចគ្នាដែរ សូមមើលមាត្រា ២១(៤) នៃវិធានផ្ទៃក្នុង ដែលបានចែងថា ជនត្រូវចោទមានសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

[12] សូមមើលត្រង់ចំណុចដែលបានគូសចំណាំ។

[13] ការអធិប្បាយជាទូទៅរបស់CCPR លេខ៨ៈ សិទ្ធិក្នុងការទទួលបាននូវសេរីភាព និងសុវត្ថិភាពផ្ទាល់ខ្លួន (មាត្រា៩)ៈ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៨២។

*<u>ជម្រះ</u> គណៈកម្មាធិការរំលឹកអំពីយុត្តិសាស្ត្ររបស់ខ្លួនថា "[ ក្នុង ] <u>ករណីពាក់ព័ន្ធជាមួយបទចោទប្រកាន់លើបទល្មើសធ្ងន់ធ្ងរ ដូចជាករណីមនុស្សឃាត ឬ មនុស្សឃាតដោយចេតនា និងក្នុងករណីជនជាប់ចោទត្រូវបានបដិសេធ ដោយតុលាការនូវសំណើឱ្យនៅក្រៅឃុំដោយតំកល់ប្រាក់ធានា ដូច្នេះជនជាប់ចោទត្រូវតែទទួលបានការជំនុំជម្រះយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើបាន</u>"[15] ។ ចំពោះរឿងក្តីបច្ចុប្បន្ន ជនជាប់ចោទត្រូវបានចាប់ខ្លួននៅថ្ងៃប្រព្រឹត្តបទល្មើស ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត និងត្រូវឃុំខ្លួនរហូតដល់ថ្ងៃសវនាការ ហើយភស្តុតាងទាក់ទងនឹងអង្គហេតុមិនស្មុគស្មាញ ហើយប៉ូលីស ក៏មិនចាំបាច់ធ្វើការស៊ើបអង្កេតច្រើនពេកដែរ គណៈកម្មាធិការពិចារណាថា <u>ត្រូវតែបង្ហាញមូលហេតុច្រើនគួរសម ដើម្បីធ្វើយុត្តិកម្មចំពោះការពន្យារពេលឃុំខ្លួនរយៈពេល២២ខែ រហូតដល់ថ្ងៃសវនាការ</u> ។ រដ្ឋជាភាគីគ្រាន់តែលើកឡើងនូវបញ្ហាទូទៅ និង អំពីបញ្ហាអស្ថិរភាពក្រោយការប៉ុនប៉ងធ្វើរដ្ឋប្រហារ ហើយទទួលស្គាល់ថាការពន្យារពេលពិតជាកើតឡើងមែន ។ ក្នុងកាលៈទេសៈបែបនេះ គណៈកម្មាធិការសន្និដ្ឋានថា សិទ្ធិរបស់ជនជាប់ចោទការពារដោយមាត្រា ៩(៣) និង មាត្រា ១៤(៣-គ) ត្រូវបានរំលោភ*[16]" ។

48. ដូចគ្នាដែរ គណៈកម្មាធិការសិទ្ធិមនុស្សបានយល់ឃើញថាមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិត្រូវបានរំលោភបំពាន នៅក្នុងរឿង កូណេ(Kone) តទល់នឹងសេនេហ្គាល[17] សំរាប់មូលហេតុដូចខាងក្រោមនេះ៖

*<u>នៅពេលអវត្តមានកាលៈទេសៈ</u>ដើម្បីធ្វើយុត្តិកម្មការពន្យាពេលបែបនេះ ដូចជាមានការស៊ើបអង្កេត ឬមានឧបសគ្គដល់ការស៊ើបអង្កេត<u>ដែលជាបច្ច័យដល់ជនជាប់ចោទ ឬ តំណាងរបស់គាត់</u>។ <u>ការពន្យាពេលបួន(៤) ឆ្នាំ និងបួន(៤)ខែ</u> ដែលក្នុងចិរវេលានេះជនជាប់ចោទជាប់ឃុំក្នុងពន្ធនាគារ (ពិចារណាពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទដែលមិនទាន់បានសម្រេចរហូតដល់នៅថ្ងៃដោះលែងគាត់បណ្តោះអាសន្ននាថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៨៦) <u>រំលោភនឹងបទបញ្ញត្តិក្នុងមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិ</u>* [18]។

---

[14] លិខិតទំនាក់ទំនង លេខ៨១៨/១៩៩៨ Sextus តទល់នឹង Trinite និងTobago (អនុសាសន៏របស់គណៈកម្មការ ក្នុងការប្រជុំលើកទី៧២ ចុះថ្ងៃទី១៦ កក្កដា ២០០១) វាក្យខ័ណ្ឌ៧.២។

[15] រឿងក្តីBarroso តទល់នឹងប៉ាណាម៉ា(លិខិតទំនាក់ទំនង លេខ៤៧៣/១៩៩១) វាក្យខ័ណ្ឌ៨.៥។

[16] សូមមើលត្រង់ចំណុចដែលបានគូសចំណាំ។

[17] លិខិតទំនាក់ទំនង ៣៨៦/១៩៨៩ ករណី(Kone) តទល់នឹងសេនេហ្គាល (អនុសាសន៏របស់គណៈកម្មការ ចុះថ្ងៃទី២១ តុលា ១៩៩៤) វាក្យខ័ណ្ឌ៨.៧។

[18] សូមមើលត្រង់ចំណុចដែលបានគូសចំណាំ។

49. ជាបញ្ចប់ក្នុងរឿងក្តីពីឡាស្រ្ត(Pillastre) និងប៊ីហ្សួន(Bisouarn) តទល់នឹងបូលីវី[19] គណៈកម្មាធិការសិទ្ធិមនុស្សបានទាត់ចោលនូវអំណះអំណាងផ្សេងៗ ដែលរដ្ឋបានលើកឡើង ដើម្បីព្យាយាមអះអាងអំពីរយៈពេល លើសកំណត់នៃការការឃុំខ្លួនអ្នកតវ៉ានេះ ដោយលើកហេតុផលដូចខាងក្រោមនេះ៖

*“(...)ដោយសារតែថវិកាមិនគ្រប់គ្រាន់ សំរាប់ការគ្រប់គ្រងយុត្តិធម៌ព្រហ្មទណ្ឌដែលប្រខិតឡើង រដ្ឋជាភាគីក៏មិនបានធ្វើយុត្តិកម្មចំពោះការពន្យាពេលមិនសមហេតុផលក្នុងការកាត់សេចក្តីរឿងក្តីព្រហ្មទណ្ឌដែរ ។ តាមការពិតការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌ ត្រូវអនុវត្តទៅតាមមធ្យោបាយដែលកំណត់ដោយនីតិវិធីជាលាយលក្ខណ៍អក្សរ នេះបើតាមការយល់ឃើញរបស់ពួកគេ ដើម្បីធ្វើយុត្តិកម្មលើការពន្យាពេល ។ ក្នុងរឿងក្តីបច្ចុប្បន្ន គណៈកម្មាធិការមិនត្រូវបានជូនដំណឹងអំពីសេចក្តីសំរេចរបស់សាលាដំបូងដែលធ្វើឡើង កាលពីបួនឆ្នាំមុន ភ្លាមៗបន្ទាប់ពីចាប់ខ្លួនជនរងគ្រោះ ។ បើពិចារណាអំពីការប្រមូលភស្តុតាង ក៏មិនបានធ្វើយុត្តិកម្មចំពោះការពន្យាពេលនៃការឃុំខ្លួននេះដែរ ។ ក្នុងបរិបទនេះ គណៈកម្មាធិការសន្និដ្ឋានថាពិតជាមានការរំលោភលើមាត្រា ៩(៣)” ។*

50. គួរកត់សំគាល់ថា ក្នុងសេចក្តីសំរេចរបស់ខ្លួន តុលាការព្រហ្មទណ្ឌអន្តរជាតិតែងតែយោងមិនត្រឹមតែទៅលើសេចក្តីសំរេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែក៏យោងលើសាលក្រមរបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ដើម្បីជួយឲពួកគេអាចអនុវត្ត និងបកស្រាយនូវសំណួរគតិយុត្តិ ឬវិធាននីតិវិធីផងដែរ[20]។

---

[19] លិខិតទំនាក់ទំនង ៣៣៦/៨៨ ករណីPillastre et Bisouarn តទល់នឹងBolivie (អនុសាសន៍របស់គណៈកម្មការ ចុះថ្ងៃទី៦ វិច្ឆិកា ១៩៩១) វាក្យខ័ណ្ឌ៦.៥។

[20] ជាឧទាហរណ៍ រឿងក្តី ព្រះរាជអាជ្ញា តទល់នឹងបារ៉ាយ៉ាហ្គីហ្សា(Barayagwiza) ថ្ងៃទី៣ វិច្ឆិកា ១៩៩៩ សាលាឧទ្ធរណ៍ តុលាការ ព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា វាក្យខ័ណ្ឌ៤០ ដែលបានកំណត់ដូចខាងក្រោមនេះ៖ *កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ជាផ្នែកមួយនៃច្បាប់អន្តរជាតិទូទៅ និង អនុវត្តចំពោះមូលដ្ឋាននេះដែរ ។ សន្ធិសញ្ញាក្នុងតំបន់ ដូចជាអនុសញ្ញាអឺរ៉ុប ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងយុត្តិសាស្រ្តដែលបង្កើតឡើងក្រោមច្បាប់អន្តរជាតិទាំងនេះ អាចជាជំនួយក្នុងការអនុវត្ត និងបកស្រាយច្បាប់ដែលអនុវត្តនៅតុលាការ ។ ប៉ុន្តែច្បាប់អន្តរជាតិទាំងនេះជាភស្តុតាងនៃទំនៀមទំលាប់អន្តរជាតិ ។* សូមមើល រឿងក្តីព្រះរាជអាជ្ញាតទល់នឹង Hadzihasanovic, សាលាដំបូង តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសយូហ្គូស្លាវី សេចក្តីសំរេចឲមានការដោះលែងជាបណ្តោះអាសន្នលោក Enver Hadzihasanovic ថ្ងៃទី១៩ ធ្នូ ២០០១ វាក្យខ័ណ្ឌ៦ និង៧ បានកំណត់ថា៖ *វិធាន ៦៥ ត្រូវតែបានអានដោយយោងទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ហើយថានៅតុលាការអន្តរជាតិការឃុំខ្លួនមុនការជំនុំជម្រះត្រូវតែជាអញ្ញត្រកម្មមិនមែនជាវិធានឡើយ ហើយជាចុងក្រោយថា ការឃុំខ្លួនជាបង្ខំរបស់តុលាការទៅលើការបញ្ជូនត្រូវតែមានវិសមិតភាពជាមួយមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។*

51. មេធាវីការពារក្តីក្តីសូមរំលឹកឡើងវិញថាតុលាការអឺរ៉ុបបានបកស្រាយដូចគ្នានូវសញ្ញាណនៃរយៈពេលសមស្រប ដូចនឹងការបកស្រាយរបស់គណៈកម្មាធិការសិទ្ធិមនុស្សដែរ។

52. ក្នុងរឿងក្តីជាច្រើនតុលាការអឺរ៉ុបបានសំរេចថាការឃុំខ្លួនដែលបើទោះជាមានរយៈពេលតិចជាង៨ឆ្នាំក៏ដោយ ក៏ជាការរំលោភបំពានលើមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដែរ[21]។

53. ដោយឡែក នៅក្នុងសេចក្តីសំរេចរបស់ខ្លួន តុលាការអឺរ៉ុបបាននិយាយយ៉ាងជាក់លាក់ជារហូតមកថា ទោះបីជាមូលហេតុ ដែលអាជ្ញាធរមានសមត្ថកិច្ចបានលើកឡើងដើម្បីអះអាងពីការឃុំខ្លួននោះ មានលក្ខណៈសមហេតុផល និងគ្រប់គ្រាន់[22]ក៏ដោយ ក្នុងរឿងក្តីនីមួយៗ គឺត្រូវមានការកំណត់អោយដឹងថា "តើអាជ្ញាធរជាតិដែលមានសមត្ថកិច្ចនោះ "បានធ្វើការប្រុងប្រយ័ត្នជាពិសេស" ចំពោះបណ្តឹងលើនីតិវិធីដែរឬទេ?"[23]។ ដោយពុំមានការបង្ហាញពីការប្រុងប្រយ័ត្ននេះពីសំណាក់អាជ្ញាធរយុត្តិធម៌ តុលាការបានសំរេចថាមានការរំលោភទៅសិទ្ធិរបស់អ្នកប្តឹងសុំ ក្នុងការទទួលបានជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ដែលបានធានាដោយមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

54. នៅក្នុងសាលក្រមរបស់ខ្លួនរឿងហ្វូសឺឡាំងតទល់ជាមួយបារាំង តុលាការអឺរ៉ុបបានកត់សំគាល់ថា៖ ភាពអសកម្មជាច្រើនឆ្នាំកន្លងមកគឺបណ្តាលមកពីអាជ្ញាធរយុត្តិធម៌ ហើយរយៈពេលដ៏យូរនៃការឃុំខ្លួនបណ្តោះអាសន្នអ្នកប្តឹងសុំនេះដែលបណ្តាលមកពីភាពកកស្ទះនៃរឿងក្តីដ៏ច្រើន ដែលកំពុងរង់ចាំជំនុំជម្រះពីតុលាការឧក្រិដ្ឋ។ បន្ទាប់ពីបានលើកឡើងថា "វាជាបន្ទុករបស់រដ្ឋដែលជាអ្នកត្រូវរៀបចំនូវប្រពន្ធ័យុត្តិធម៌ក្នុងប្រទេសខ្លួន ដោយធ្វើយ៉ាងណាឲតុលាការរបស់ខ្លួនអាចឆ្លើយតបទៅនឹងការទាមទារក្នុងមាត្រា ៥"រួចមក តុលាការបានសំរេចថា មាត្រា៥(៣)ត្រូវបានរំលោភបំពាន ដោយហេតុថា "អាជ្ញាធរពុំបានបង្ហាញនូវភាពរហ័សរហួនដែលជាការចាំបាច់ ហើយបើទោះបីជាអ្នកប្តឹង

[21] សូមមើល ជាឧទាហរណ៍ រឿងក្តី ផាន់ហ្សែល(Punzelt) តទល់នឹងសាធារណរដ្ឋឆែក - រយៈពេលឃុំខ្លួន ២ឆ្នាំ ៦ខែ និង១៨ថ្ងៃ - ឡាប៊ីតា(Labita) តទល់នឹងអ៊ីតាលី - រយៈពេលឃុំខ្លួន ២ឆ្នាំ និង៧ខែ - ហ្សេស៊ីស(Jecius) តទល់នឹងលីទុយអានី(Littuanie) - រយៈពេលឃុំខ្លួន ១៣ខែ និង១៦ថ្ងៃ - វ៉ាការ៉ូ(Vaccaro) តទល់នឹងអ៊ីតាលី - រយៈពេលឃុំខ្លួន ៤ឆ្នាំ និង៨ខែ - គត់ឡា(Kudhla) តទល់នឹងប៉ូឡូញ - រយៈពេលឃុំខ្លួន ២ឆ្នាំ ៤ខែ និង៣ថ្ងៃ - អ៊ីលីយ៉ូវេគី(Iliowiecki) តទល់នឹងប៉ូឡូញ- រយៈពេលឃុំខ្លួន ១ឆ្នាំ ៩ខែ និង១៩ថ្ងៃ។ ឧទាហរណ៍ទាំងនេះត្រូវបានដកស្រង់ចេញពីសៀវភៅដែលមានចំណងជើងថា "មគ្គុទេសន៏អនុវត្តអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស" (A Practitioners Guide to the European Convention on Human Rights) ដោយខារិន រ៉េដ (Karen Reid)។

[22] មេធាវីការពារក្តីយល់ឃើញថា នៅពេលនេះ មូលហេតុទាំងនេះពុំមានអត្ថិភាពឡើយ (សូមមើលបន្តបន្ទាប់ពីនេះ)។

[23] ហ្សេរ៉ា ប៊ែណា (Gerard Bernard)តទល់នឹងបារាំង ថ្ងៃទី២៦ ធ្នូ ២០០៦ វាក្យខ័ណ្ឌ ៣៧ រួមទាំងសាលដីកាសំខាន់ៗទៀតដូចជា ករណីលេតឺលីយេ តទល់នឹងបារាំង ថ្ងៃទី២៦ មិថុនា ១៩៩១ វាក្យខ័ណ្ឌ ៣៥ ករណីអ៊ីអា (I.A.) តទល់នឹងបារាំង ថ្ងៃទី២៣ កញ្ញា ១៩៩៨ វាក្យខ័ណ្ឌ ៣៥ ករណីហ្សានុទី(Zannouti) តទល់នឹងបារាំង ថ្ងៃទី ៣១ កក្កដា ២០០១ វាក្យខ័ណ្ឌ ៤៣។

សុំពុំបានបង្ហាញពីភាពរារាំងដោយផ្នែកណាមួយដល់ដំណើរការនៃនីតិវិធី” ដោយគាត់គ្រាន់តែប្រើប្រាស់សិទ្ធិរបស់គាត់ ក្នុងការធ្វើបណ្ដឹងផ្សេងៗយ៉ាងត្រឹមត្រូវ និងសមហេតុផលតែប៉ុណ្ណោះ”[24]។

55. មេធាវីការពារក្ដីសូមអះអាងថា ក្នុងរឿងក្ដីនេះលោក **កាំង ហ្គេកអ៊ាវ** ពុំបានទទួលការកាត់ក្ដី“ក្នុងរយៈពេលលឿនបំផុតដែលអាចទៅរួច ឬត្រូវបានដោះលែង” ដូចដែលបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្សខាងលើនេះបានទាមទារឡើយ។

56. ផ្ទុយទៅវិញ អាជ្ញាធរយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងសំណុំរឿងនេះបានឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** អស់ពេលជាង៨ឆ្នាំទៅវិញ ដោយពុំបានផ្ដល់មូលហេតុដើម្បីធ្វើយុត្តិកម្មលើការឃឹតយ៉ាវនេះឡើយ។

57. ទី១ មេធាវីការពារក្ដីសូមលើកឡើងថា ចៅក្រមស៊ើបអង្កេតនៅតុលាការយោធាពុំបានបញ្ជាក់ពីមូលហេតុណាមួយដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្ដោះអាសន្នលោក **កាំង ហ្គេកអ៊ាវ**ឡើយ[25]។

58. ទី២ មេធាវីការពារក្ដីកត់សំគាល់ឃើញថា មូលហេតុនៃការឃឹតយ៉ាវនេះហាក់ដូចជាអាជ្ញាធរទាំងនោះចង់អោយលោក **កាំង ហ្គេកអ៊ាវ** ទទួលជំនុំជម្រះពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវរង់ចាំជាច្រើនឆ្នាំទៀតសិនដើម្បីបង្កើតអង្គជំនុំជម្រះនេះ។

59. អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមឲអង្គបុរេជំនុំជម្រះសំរេចថា ក្នុងរឿងក្ដីនេះ ចំពោះរយៈពេលឃុំខ្លួនចំនួន៨ឆ្នាំពិតជាហួសកំរិតពីបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស។

60. មេធាវីការពារក្ដីសូមអោយអង្គបុរេជំនុំជម្រះពិនិត្យមើលថា យើងមិនអាចទំលាក់កំហុសទៅលើលោក **កាំង ហ្គេកអ៊ាវ** ឬមេធាវីការពារក្ដីរបស់គាត់បានទេ ប៉ុន្តែផ្ទុយមកវិញវាជាកំហុសរបស់អាជ្ញាធរយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងរឿងក្ដីនេះទាំងស្រុង។

61. ជាវិបាក មេធាវីការពារក្ដីសូមអោយអង្គបុរេជំនុំជម្រះសំរេចសេចក្ដីថា មានការរំលោភលើសិទ្ធិរបស់លោក **កាំង ហ្គេកអ៊ាវ** ក្នុងការទទួលបាននូវជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ដោយអនុលោមតាម មាត្រា ៩ (៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ។

**(២) ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានសមត្ថកិច្ច ក្នុងការពិចារណាពីផលវិបាកគតិយុត្តិដែលបណ្ដាលមកពីការរំលោភបំពានលើច្បាប់នេះ**

---

[24] រឿងហ្គូសឺឡាំង(Gosselin) តទល់បារាំង ថ្ងៃទី១៣ កញ្ញា ២០០៥ វាក្យខ័ណ្ឌ ៣៥។

[25] សូមមើលដីកាសំរេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ ២០០៣ និង២០០៤ និងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ២០០៦ និង ២០០៧។

62. សហចៅក្រមស៊ើបអង្កេតកត់សំគាល់ថា៖ *នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីតុលាការយោធា (លោក **កាំង ហ្កេកអ៊ាវ**)ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយគាត់ក៏ត្រូវបានជាប់ឃុំចាប់តាំងពីពេលនោះមក និងជាការប្រាកដណាស់ថា ការឃុំខ្លួននេះចោទជាបញ្ហាចំពោះការគោរពបទដ្ឋានផ្នែកយុត្តិធម៌ និងដែលជាពិសេសចំពោះមាត្រា៩(៣) និង១៤(៣-គ) នៃកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងនយោបាយ*[26]។

63. ដោយឡែក សហចៅក្រមស៊ើបអង្កេតបានប្រកាសថា ខ្លួនពុំមានសមត្ថកិច្ចក្នុងការ"*វាយតំលៃអំពីនីត្យានុកូលភាពនៃការឃុំខ្លួនលោក **កាំង ហ្កេកអ៊ាវ**ក្នុងរយៈពេលកន្លងមកឡើយ*"[27]។

64. មេធាវីការពារក្តីសូមអោយអង្គបុរេជំនុំជម្រះទទួលស្គាល់ថាសិទ្ធិរបស់លោក **កាំង ហ្កេកអ៊ាវ** ក្នុងការទទួលបាននូវការកាត់ក្តីក្នុងរយៈពេលមួយសមស្រប ឬដោះលែង ត្រូវបានរំលោភបំពាន (ដូចបានលើកឡើងពីមុននេះ) ហើយសូមឲអង្គបុរេជំនុំជម្រះពិចារណាពីផលវិបាកគតិយុត្តិដែលកើតឡើងពីការរំលោភបំពាននេះ។

65. មេធាវីការពារក្តីក៏សូមលើកឡើងដែរថា ការដែលចេញដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នលោក**កាំង ហ្កេកអ៊ាវ** សំរាប់ឆ្នាំទី៩នេះ សហចៅក្រមស៊ើបអង្កេតខ្លួនឯងក៏បានចូលរួមក្នុងការឃុំខ្លួនលោក**កាំង ហ្កេកអ៊ាវ** លើសពីរយៈពេលដែលច្បាប់បានកំណត់ ហើយតាមរយៈទង្វើនេះក៏បានធ្វើអោយមានសុពលភាពនូវនីតិវិធីនៃការឃុំខ្លួនកន្លងមក ទោះបីជាវាផ្ទុយនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្សក៏ដោយ។

66. ដូច្នេះមេធាវីការពារក្តីសូមឲអង្គបុរេជំនុំជម្រះទទួលស្គាល់ថា ខ្លួនមានសមត្ថកិច្ចក្នុងការដោះស្រាយសំណួរ និងនិយាយថា ការឃុំខ្លួនអស់រយៈពេល៩ឆ្នាំនេះហួសកំរិត និងផ្ទុយនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស និងជាចុងក្រោយ ពិចារណាអំពីផលវិបាកគតិយុត្តិដែលបណ្តាលមកពីការរំលោភសិទ្ធិនេះ។

67. ធាតុផ្សំដែលបានបង្ហាញខាងលើនេះគឺដើម្បីធ្វើជាអំណះអំណាងក្នុងការការពារក្តីនេះ។

68. ជាដំបូង ទំនាក់ទំនងរវាងការពន្យារឃុំខ្លួនបណ្តោះអាសន្នលោក **កាំង ហ្កេកអ៊ាវ** ដោយចៅក្រមស៊ើបអង្កេតនៃតុលាការយោធា និងបណ្តឹងនាពេលខាងមុខនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺពិតស្តែងណាស់។

---

[26] សូមមើលដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ កក្កដា ២០០៧។

[27] សូមមើលវាក្យខ័ណ្ឌ ២ នៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

69. វាអាចធ្វើអោយទុកចិត្តគ្រប់គ្រាន់បាន ដោយគ្រាន់តែពិនិត្យមើលដីកាសំរេចឃុំខ្លួន ចុះថ្ងៃទី២២ កុម្ភៈ ២០០២ និងដីកាបន្តបន្ទាប់ទៀតរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ក្រុងភ្នំពេញ និងដែលយោងលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០១ ដើម្បីធ្វើយុត្តិកម្មបញ្ជាក់អះអាងពីការឃុំខ្លួនលោក**កាំង ហ្គេកអ៊ាវ** និងការបន្តឃុំខ្លួនគាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បន្ទាប់មកអំពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ[28]។

70. តាមរយៈសំណុំរឿងនេះដែរ យើងឃើញថាចៅក្រមស៊ើបអង្កេតនៅតុលាការយោធាពុំបានចេញដីកាសំរេចលើកលែងការចោទប្រកាន់ ឬដីកាអនុញ្ញាតឲពិគ្រោះសំណុំរឿងនៅតុលាការយោធាសំរាប់រឿងក្តីនៅពេលខាងមុខ ដែលតាមពិតចៅក្រមស៊ើបអង្កេតគួរតែចាត់វិធានការណ៏ចេញដីកានេះ ដោយហេតុថា អស់រយៈពេលជាង៨ឆ្នាំមកហើយដែលគេបានបើកការស៊ើបអង្កេតលើលោក **កាំង ហ្គេកអ៊ាវ**នេះ។

71. ជាជាក់ស្តែងណាស់ លោក **កាំង ហ្គេកអ៊ាវ**ត្រូវបានបន្តឃុំខ្លួន ដោយរង់ចាំការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា និងជំនុំជម្រះលើរឿងក្តីរបស់គាត់នៅតុលាការនេះក្នុងពេលអនាគត។

72. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចបដិសេធពីការណ៏នេះ ហើយដូច្នេះ អង្គជំនុំជម្រះត្រូវពិចារណាលើផលវិបាកគតិយុត្តិរបស់វា។

73. ដូចគ្នាដែរ នីតិវិធីដែលបានយកមកអនុវត្តក្នុងរឿងក្តីលោក **កាំង ហ្គេកអ៊ាវ**នៅតុលាការយោធា និងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទំនាក់ទំនងគ្នានៅខាងក្នុង ហើយឯកសារមួយចំនួនក្នុងសំណុំរឿងនៅតុលាការយោធាត្រូវបានបញ្ចូលមកដាក់ក្នុង សំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ។

74. ជាចំណុចទី២ មេធាវីការពារក្តីសូមរំលឹកឡើងវិញជូនអង្គបុរេជំនុំជម្រះថា ក្នុងករណីចាំបាច់ ដូចដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីការបស់ខ្លួន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ៖ *កិច្ចព្រមព្រៀង ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល*

[28] សូមមើលដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ ២០០៣ និង២០០៤ និងនៅ ថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០០៥ ២០០៦ និង ២០០៧។

*កម្ពុជាចែងយ៉ាងច្បាស់ក្នុងមាត្រា ១២ ថា អង្គជំនុំជម្រះវិសាមញ្ញបំពេញមុខងាររបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌*[29]។

75. ដូចគ្នាដែរ គោលការណ៍នេះត្រូវបានចែងយ៉ាងច្បាស់ ក្នុងមាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០៤។

76. ដោយឡែក វិធានផ្ទៃក្នុងសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ២១(១) បានចែងអំពីគោលការណ៍គ្រឹះមួយដែលថា៖ *ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ......* ។ល។

77. អាស្រ័យហេតុនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងអោយគោរពទៅតាមបទដ្ឋានអន្តរជាតិផ្នែកសិទ្ធិមនុស្សយ៉ាងពេញទំហឹង ដូច្នេះចៅក្រមរបស់អង្គជំនុំជម្រះត្រូវអនុវត្តសិទ្ធិរបស់ជនត្រូវចោទអោយមានប្រសិទ្ធិភាព និងដោយពុំគ្រាន់តែជាទ្រឹស្តីតែប៉ុណ្ណោះឡើយ។

78. ដើម្បីសំរេចតាមគោលបំណងនោះ សេចក្តីសំរេចរបស់តុលាការអឺរ៉ុបទាំងអស់សុទ្ធតែពាក់ព័ន្ធសំរាប់អោយជាសញ្ញាណដល់អង្គជំនុំជម្រះថា តើអ្វីដែលជាការអនុវត្តជាក់ស្តែងអំពី"សិទ្ធិទទួលបាននូវការកាត់ក្តីក្នុងអំឡុងពេលមួយដ៏សមស្រប" ដូចដែលបានធានាដោយមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

79. ដូច្នេះ សេចក្តីសំរេចមួយចំនួនដែលបានចេញដោយតុលាការការអឺរ៉ុបដែលទាក់ទងនឹងមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សុទ្ធតែមានតំលៃសំរាប់ការពិចារណារបស់យើង ពីព្រោះវាបង្ហាញអោយយើងឃើញថា ម្យ៉ាង រយៈពេលនៃការឃុំខ្លួនត្រូវចាប់ផ្តើមគិតតាំងពីថ្ងៃចាប់ខ្លួន ឬឃុំខ្លួនដំបូងអ្នកប្តឹងសុំមកម្ល៉េះ ហើយម្យ៉ាងទៀត រយៈពេលនៃការឃុំខ្លួនដែលបានធ្វើឡើង នៅមុនពេលដែលតុលាការអឺរ៉ុបចាប់ផ្តើមមានសមត្ថកិច្ចក៏ត្រូវរាប់បញ្ចូលផងដែរ។

80. េហេតុដូច្នេះហើយបានជានៅក្នុងសេចក្តីសំរេច ទាក់ទងនឹងរឿងក្តីរវាងមែនសួរ (Mansur) និងប្រទេសទួរគី ដែលធ្វើឡើងនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ១៩៩៥ តុលាការអឺរ៉ុបពិចារណាថា[30]៖

---

[29] សូមមើលវាក្យខ័ណ្ឌ ៣ នៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

[30] រឿងក្តីម៉ង់សួរ តទល់នឹងប្រទេសទួរគី ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៥ វាក្យខ័ណ្ឌ៥១។

*"ផ្អែកតាមសេចក្តីសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៤៤ នៃសាលក្រមនេះ តុលាការអាចពិចារណាតែរយៈពេល ១ឆ្នាំ និង ២៨ថ្ងៃ ដែលជាពេលវេលាកន្លងផុតរវាងថ្ងៃដាក់តំកល់សេចក្តីថ្លែងការណ៍ដែលប្រទេស**ទួរគី** ទទួលស្គាល់យុត្តាធិការចាប់បង្ខំរបស់តុលាការ(ថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩០) និងសាលក្រមរបស់តុលាការដំបូង Edirne Assize (ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩១) ។ <u>ប៉ុន្តែនៅពេលសំរេចថា តើការបន្តឃុំខ្លួនរបស់អ្នកប្តឹងសុំក្រោយថ្ងៃទី២២ ខែមករា ១៩៩០ មានយុត្តិកម្មក្រោមមាត្រា ៥ វាក្យខ័ណ្ឌ ៣ (មាត្រា ៥(៣)) នៃអនុសញ្ញា ឬយ៉ាងណា? តុលាការត្រូវពិចារណាទៅលើពេលវេលា៥ឆ្នាំ និង ៣ខែ ដែលអ្នកប្តឹងសុំស្ថិតនៅក្នុងក្រោមការឃុំខ្លួនចាប់តាំងពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៨៤</u> (សូមអានវាក្យខ័ណ្ឌ ២៣ខាងលើ)"*[31] ។ ក្នុងករណីនេះតុលាការបានសំរេចថា មានការរំលោភបំពានលើមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបនេះ។

81. ការសំរេចផ្ទុយពីនេះនឹងផ្ទុយស្រឡះពីកម្មវត្ថុរបស់តុលាការអឺរ៉ុបដែលដូចគ្នានឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ គឺត្រូវអនុវត្តទៅតាមនិយាមសិទ្ធិមនុស្សអន្តរជាតិ ប្រកបដោយប្រសិទ្ធិភាព។

82. ដូចគ្នាដែរ មេធាវីការពារក្តីសូមគាំទ្រសាលដីការបស់សាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា ក្នុងរឿងក្តីរបស់លោកបារ៉ាវ៉ាកហ្គីហ្សា (Barawagwiza) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលបានសំរេចយ៉ាងច្បាស់លាស់អំពីគោលការណ៍ដែលថា តុលាការព្រហ្មទណ្ឌអន្តរជាតិដែលទើបនឹងទទួលរឿងក្តីមួយ ត្រូវតែគិតអំពីរយៈពេលនៃការឃុំខ្លួនជនត្រូវចោទកន្លងមក មុនកាលដែលខ្លួនទទួលរឿងក្តីនេះ បើទោះជារយៈពេលនៃការឃុំខ្លួននេះ ត្រូវបានសំរេចដោយតុលាការមួយផ្សេងទៀតក៏ដោយ។ ដូច្នេះ បន្ទាប់ពីបានទទួលបណ្តឹងហើយ តុលាការនេះនឹងមានសមត្ថកិច្ចក្នុងការសំរេចសេចក្តីលើអំណះអំណាង ដែលជនត្រូវចោទបានលើកឡើង។

83. នៅក្នុងសេចក្តីសំរេចនេះ តុលាការអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដាបានកំណត់ថា៖

*"នៅក្នុងករណីបច្ចុប្បន្ន អ្នកដាក់បណ្តឹងឧទ្ធរណ៍ត្រូវឃុំខ្លួនអស់រយៈពេល ១១ខែ មុនទទួលការជូនដំណឹងអំពីការចោទប្រកាន់ដោយព្រះរាជអាជ្ញា។ ប៉ុន្តែតុលាការដឹងថា មានតែ៣៥ថ្ងៃ នៃថិរវេលានៃការឃុំខ្លួនសរុបប៉ុណ្ណោះ ដែលអាចទំលាក់កំហុសលើតុលាការការអំពីការឃុំខ្លួនអ្នកប្តឹងឧទ្ធរណ៍ (ចាប់ពីថ្ងៃ ១៧ ខែមេសា ដល់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៦ និងពីថ្ងៃទី៤ ដល់ថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៧) នេះមានន័យថា អ្នកប្តឹងឧទ្ធរណ៍ស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នយ៉ាងវែង ដោយពុំមានការជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងមកលើរូបគាត់ ។ ខណៈនេះវាមិនពាក់ព័ន្ធទេ បើទោះបីពេលវេលានៃការឃុំខ្លួនដ៏ខ្លីស្ថិតនៅក្រោមការឃុំខ្លួនរបស់តុលាការក៏ដោយ ដោយសារវាជាតុលាការ-វាមិនមែនជាស្ថានប័ននីតិបុគ្គលផ្សេង*

---

[31] សូមមើលចំណុចដូចដែលបានគូសពីក្រោម។ ដូចគ្នាដែរ សូមមើលសាលដីការបស់តុលាការអឺរ៉ុបក្នុងរឿងក្តីកាឡាសនីកូវ (Kalachnikov) តទល់នឹងប្រទេសរូស្ស៊ី ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០២ វាក្យខ័ណ្ឌ ១១១។

*ឯណា-ដែលបច្ចុប្បន្ននេះ កំពុងកាត់សេចក្តីលើការទាមទាររបស់អ្នកប្តឹងឧទ្ធរណ៍ ។ ដោយមិនពិចារណាថា តើភាគីណាត្រូវទទួលខុសត្រូវក្នុងការឃុំខ្លួននេះ សិទ្ធិរបស់អ្នកប្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជូនដំណឹងអំពីបទចោទត្រូវបានរំលោភបំពាន ។"*

**(៣) លោក កាំង ហ្គេកអ៊ាវត្រូវតែបានដោះលែង ហើយប្រសិនបើចាំបាច់ គាត់អាចត្រូវដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

84. មេធាវីការពារក្តីយល់ឃើញថាមានតែការដោះលែងលោក **កាំង ហ្គេកអ៊ាវ** អោយមានសេរីភាពភ្លាមៗតែប៉ុណ្ណោះ ទើបអាចដោះស្រាយបានមួយចំណែកអំពីបញ្ហារំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបាន ជំនុំជម្រះក្នុងរយៈពេលមួយសមស្របបាន។

85. មេធាវីការពារក្តីកត់សំគាល់ឃើញថា តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងឡាយ តែងតែយល់ព្រមដល់សំណើសុំដាក់អោយនៅក្រៅឃុំដែលមានលក្ខណៈប្រហាក់ប្រហែល សំរាប់បុគ្គលដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋដែលមានកំរិតធ្ងន់ធ្ងរដូចលោក **កាំង ហ្គេកអ៊ាវ** ដែរ[32]។

86. ដូច្នេះ មេធាវីការពារក្តីសូមសំណូមពរអោយអង្គបុរេជំនុំជម្រះមេត្តាអនុញ្ញាតអោយដោះលែងលោក **កាំង ហ្គេកអ៊ាវ** ជាបន្ទាន់ ហើយប្រសិនបើចាំបាច់ អាចដាក់គាត់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ដោយធ្វើការកំណត់និវេសណដ្ឋានឱគាត់។

## ខ <u>អំពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួនជាបណ្តោះអាសន្នដែលសំរេចដោយសហចៅក្រមស៊ើបអង្កេត</u>

**87.** ប្រសិនបើអង្គបុរេជំនុះជម្រះផ្តល់សុពលភាពលើដីកាសំរេចដែលបានប្តឹងឧទ្ធរណ៍នេះ ដោយលើកហេតុផលថា សហចៅក្រមស៊ើបអង្កេតពុំមានសមត្ថកិច្ចសំរេចអំពីអនីត្យានុកូលភាព នៃការឃុំខ្លួនជាបណ្តោះអាសន្នរយៈជាង៨ឆ្នាំ ដែលបានសំរេចដោយចៅក្រមស៊ើបអង្កេតនៅតុលាការយោធានេះ មេធាវីការពារក្តីសូមអះអាងថា ទោះជាករណីណាក៏ដោយសហចៅក្រមស៊ើបអង្កេតត្រូវគិតអំពី

---

[32] ដូចជាឧទាហរណ៍ សូមមើលក្នុងរឿងក្តីព្រះរាជអាជ្ញា តទល់នឹងRamush Haradinaj, តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសំរេចលើបណ្តឹងរបស់ Haradinaj អំពីការដោះលែងជាបណ្តោះអាសន្ន" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ ។ លោក Haradinajត្រូវបានចោទប្រកាន់ពីបទល្មើសចំនួន៣៧ករណី ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ហើយត្រូវបានដោះលែងឱរង់ចាំការជំនុំជម្រះ រឿងក្តីព្រះរាជអាជ្ញា តទល់នឹងRahim Ademi ដីកាសំរេចឱដោះលែងជាបណ្តោះអាសន្នចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ រឿងក្តីព្រះរាជអាជ្ញា តទល់នឹងHadzihasanovic, TC សេចក្តីសំរេចឱដោះលែងជាបណ្តោះអាសន្នលោក Enver Hadzihasanovic ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១។

រយៈពេលជាង៨ឆ្នាំ ដែលបានឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ**កន្លងមក ព្រោះថាចៅក្រមត្រូវពិចារណាពីកាលានុវត្តភាពក្នុងការសំរេចឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ**សំរាប់ឆ្នាំទី៩នេះ[33] ឬក៏មិនឃុំខ្លួន ហើយថាល័ក្ខខ័ណ្ឌដើម្បីសំរេចឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ដែលបានចុះនៅថ្ងៃទី៣១ កក្កដា ២០០៧ ពុំទាន់ត្រូវបានបំពេញនៅឡើយទេ។ អាស្រ័យដូចបានជំរាបជូនខាងលើនេះ មេធាវីការពារក្តីសំណូមពរអោយចៅក្រមដោះលែងលោក **កាំង ហ្គេកអ៊ាវ**ឲមានសេរីភាព។

88. មេធាវីការពារក្តីយល់ឃើញថា ផ្ទុយទៅនឹងអ្វីដែលសហចៅក្រមស៊ើបអង្កេតបានសំរេច ល័ក្ខខ័ណ្ឌដើម្បីសំរេចឃុំខ្លួន (និងតាមពិតវាជាការបន្តឃុំខ្លួន)លោក **កាំង ហ្គេកអ៊ាវ** ជាបណ្តោះអាសន្ននេះពុំត្រូវបានបំពេញនៅឡើយទេ ។

89. សេចក្តីសំរេចឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតផ្អែកទៅលើវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងដែលបានចែងថា៖

*“សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបាន តែក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ៖*

*ក មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឲស៊ើបសួរ ឬដីកាបញ្ជូនរឿងឲស៊ើបសួរបន្ថែម។*

*ខ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់ដើម្បី:*

*(.....)*

*iii. ធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការនីតិវិធី*

*iv. ការពារសន្តិសុខអោយជនដែលត្រូវចោទ*

*v. រក្សាសណ្តាប់ធ្នាប់សាធារណៈ[34]”*

---

[33] ដើម្បីជាការគាំទ្រលើអំណះអំណាងនេះ សូមមើលសាលក្រមរបស់តុលាការអឺរ៉ុបដែលបានបង្ហាញខាងលើនេះដូចជា៖ ក្នុងរឿងក្តី Mansur តទល់នឹងទួរគីចុះថ្ងៃទី ២៣ ឧសភា១៩៩៥ វាក្យខ័ណ្ឌ៥១ ករណីKalachnikov តទល់នឹងរូស៊ី ចុះថ្ងៃទី ១៥ កក្កដា ២០០២ វាក្យខ័ណ្ឌ១១១។ ដូចគ្នាសូមមើល*រឿងក្តីព្រះរាជអាជ្ញា តទល់នឹងRahim Ademi ដីកាសំរេចឲដោះលែងជាបណ្តោះអាសន្នចុះថ្ងៃទី ២០ កុម្ភៈ ២០០២ វាក្យខ័ណ្ឌ២៦០: “...រយៈពេលនៃការឃុំខ្លួនមុនការជំនុំជម្រះ ជាកត្តាមួយដែលពាក់ព័ន្ធទៅនឹងសេចក្តីសំរេចដែលថា តើត្រូវបន្តការឃុំខ្លួនឬយ៉ាងណា? (...) វិវាទនេះទាមទារនូវការយកចិត្តទុកដាក់មួយដោយឡែក ដើម្បីពិនិត្យលើបទបញ្ញត្តិដែលបានចែងក្នុងមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។*

[34] សូមមើលមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលបានចែងអំពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួនស្រដៀងគ្នា និងដែលត្រូវបានអនុវត្តតាំងពីថ្ងៃទី២០ សីហាមកម្ល៉េះ។

90. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា លោក **កាំង ហ្កេកអ៊ាវ** ត្រូវស្ថិតនៅក្នុងការឃុំឃាំងជាបន្ត ដោយសំអាងលើមូលហេតុដូចខាងក្រោមនេះ៖

- ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ
- ដើម្បីធានាអំពីវត្តមានរបស់លោក **កាំង ហ្កេកអ៊ាវ** ក្នុងដំណើរការនីតិវិធី
- ដើម្បីការពារសន្តិសុខផ្ទាល់ខ្លួនអោយលោក **កាំង ហ្កេកអ៊ាវ**[35]

91. មេធាវីការពារក្តីសូមរំលឹកឡើងវិញអំពីយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌនៃការឃុំខ្លួនជនត្រូវចោទ ដែលមានអត្ថន័យដូចខាងក្រោមនេះ៖

*"ការមិនព្រមលះបង់នូវការសង្ស័យសមហេតុផលដែលថាជនម្នាក់ដែលត្រូវចាប់ខ្លួន បានប្រព្រឹត្តបទល្មើសមួយ ជាធាតុផ្សំ(លក្ខខណ្ឌ) [sine qua non] ដ៏សំខាន់សំរាប់សុពលភាពនៃការបន្តឃុំខ្លួន ប៉ុន្តែបន្ទាប់ពីរយៈពេលនៃការឃុំខ្លួនកន្លងផុតដ៏យូរបែបនេះ តុលាការត្រូវតែពិចារណាប្រសិនបើមូលហេតុផ្សេងទៀតដែលបានបង្ហាញដោយអាជ្ញាធរយុត្តិធម៌ ដើម្បីបន្តធ្វើយុត្តិកម្មលើការដកហូតសេរីភាពនេះ ។ ប្រសិនបើមូលហេតុទាំងនេះ គ្រប់គ្រាន់ និងសមហេតុផល តុលាការត្រូវស្វែងយល់ឲប្រាកដថា តើអាជ្ញាធរជាតិមានសមត្ថកិច្ចបាន"ព្យាយាមជាពិសេស" ដែរឬទេ ក្នុងការដំណើរការនីតិវិធី"* [36]។

92. មេធាវីការពារក្តីសូមអះអាងថាមូលហេតុដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងដើម្បីអះអាងបញ្ជាក់អំពី(ការបន្ត)ឃុំខ្លួនលោក **កាំង ហ្កេកអ៊ាវ**នោះ ពុំមានលក្ខណៈសមហេតុផល និងគ្រប់គ្រាន់ទៅតាមនិយាមស្តីពីសិទ្ធិមនុស្សនោះឡើយ។ (១)

93. មេធាវីការពារក្តីក៏សូមអះអាងដែរថា ដូចដែលបានបង្ហាញជូនពីខាងលើនេះ ទោះជាក្នុងករណីណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការ"ព្យាយាមជាពិសេស" ទៅលើបណ្តឹងលើនីតិវិធី នេះ[37]។

94. ដោយឡែក មេធាវីការពារក្តីសូមឲអង្គបុរេជំនុំជម្រះបដិសេធដីកាសំរេចឲឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ កក្កដា ២០០៧ ព្រមទាំងដោះលែងលោក **កាំង ហ្កេកអ៊ាវ**ឲមានសេរីភាព ហើយប្រសិនបើចាំបាច់អាចដាក់គាត់ អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។ (២)

---

[35] សូមមើលវាក្យខ័ណ្ឌ ២២ និង២៣នៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

[36] រឿងក្តីហ្សេរ៉ា ប៊ែកណា (Gerard Bernard) តទល់នឹងបារាំង ចុះថ្ងៃទី២៦ កញ្ញា ២០០៦ វាក្យខ័ណ្ឌ៣៧ ព្រមទាំងសាលដីកាដ៏ទៃទៀតបស់តុលាការអឺរ៉ុប ដូចជា លេតឺលីយេ (Letellier) តទល់នឹងបារាំង ចុះថ្ងៃទី២៦ មិថុនា ១៩៩១។

[37] សូមមើលអំណះអំណាងអំពីចំណុចនេះនៅក្នុងចំណុច(ក)។

១ មូលហេតុដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងដើម្បីអះអាងបញ្ជាក់អំពី(ការបន្ត)ឃុំខ្លួន លោក កាំង ហ្គេកអ៊ាវនោះ ពុំមានលក្ខណៈសមហេតុផល និងគ្រប់គ្រាន់ទៅតាមនិយាមស្តីពីសិទ្ធិមនុស្សឡើយ

95. មានចំណុចសំខាន់ដែលត្រូវកត់សំគាល់ គឺថា គណៈកម្មាធិការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានយល់ឃើញថា៖ ការឃុំខ្លួនដែលមានរយៈពេលជិត៣ឆ្នាំ ត្រូវមានមូលហេតុបញ្ជាក់ឱ្យបានច្បាស់លាស់បំផុត[38]។ ជាក់ស្តែង ការសំរេចឃុំខ្លួន (និងជាការបន្តឃុំខ្លួន)លោក **កាំង ហ្គេកអ៊ាវ** ជាបណ្តោះអាសន្នសំរាប់ឆ្នាំទី៩នេះ ពុំបានបង្ហាញនូវយុត្តិកម្មណាមួយឡើយ ដូចដែលបានលើកឡើងជាបន្តបន្ទាប់នេះ។

១ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ:

*96.* សហចៅក្រមស៊ើបអង្កេតបានចេញដីកាសំរេចឱ្យឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ដោយអះអាងថា៖ *អង្គហេតុដែលត្រូវដាក់បន្ទុកចំពោះជនត្រូវចោទមានលក្ខណៈធ្ងន់ធ្ងរ បទឧក្រិដ្ឋដែលបានកើតឡើងរយៈពេល៣០ឆ្នាំមកហើយ នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ.....*[39] ។

*97.* ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា៖ *មិនមែនជាការហួសហេតុពេកទេដែលអះអាងថា នៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជននេះអាចនឹងបង្កឱមានការសំដែងនូវការមិនពេញចិត្តជាទូទៅដែលអាចបង្កឱមានអំពើហិង្សា*[40] ។

98. មេធាវីការពារក្តីសូមរំលឹកឡើងវិញនូវយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សពីចំណុចនេះ។

99. តុលាការអឺរ៉ុបយល់ឃើញថាបុគ្គលម្នាក់អាចត្រូវបានគេឃុំខ្លួន តែក្នុងករណីដែលថា ការដោះលែងជននោះនឹងបណ្តាលឱមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងតែកាលៈទេសៈពិសេស និងក្រោមល័ក្ខខ័ណ្ឌមួយចំនួនតែប៉ុណ្ណោះ[41]។

100. ល័ក្ខខ័ណ្ឌទី១៖ ត្រូវមាន "អង្គហេតុដែលបង្ហាញថាការដោះលែងជនជាប់ឃុំនោះ នឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ"[42]។

---

[38] សូមមើលចំណុចដែលបានគូសចំណាំពីក្រោម។ សូមមើលរឿងក្តី ប៊ែកណា(Bernard) តទល់នឹងបារាំង ថ្ងៃទី២៦ ធ្នូ ២០០៦ វាក្យខ័ណ្ឌ៣៨ និងរឿងក្តី ហ្គូសសឺលីន(Gosselin) តទល់នឹងបារាំង ថ្ងៃទី១៣ កញ្ញា ២០០៥ វាក្យខ័ណ្ឌ៣២។

[39] សូមមើលវាក្យខ័ណ្ឌ ២២នៃដីកាសំរេចរបស់សហចៅក្រម។

[40] សូមមើលវាក្យខ័ណ្ឌ ២២នៃដីកាសំរេចរបស់សហចៅក្រម។

[41] សូមមើលរឿងក្តីប៊ែកណា តទល់នឹងបារាំង ថ្ងៃទី២៦ ធ្នូ ២០០៦ វាក្យខ័ណ្ឌ៤៦។

[42] ដូចគ្នា។

101. ល័ក្ខខ័ណ្ឌទី២៖ "ការឃុំខ្លួននេះស្របច្បាប់តែក្នុងករណីដែលថា ប្រសិនបើសណ្តាប់ធ្នាប់សាធារណៈនោះនៅតែត្រូវបានគំរាមកំហែងយ៉ាងខ្លាំង ពេលនោះការបន្តឃុំខ្លួននោះមិនអាចត្រូវបានប្រើប្រាស់ដោយគ្រាន់តែប្រមាណទុកជាមុនទៅលើទោស(ដោយការបំបិទសេរីភាព)របស់ជននោះឡើយ"[43]។

102. ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតបានលើកឡើងថាអង្គហេតុដែលបានដាក់បន្ទុកទៅលោក**កាំង ហ្គេកអ៊ាវ** មានការប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែចៅក្រមពុំបានបង្ហាញនូវធាតុផ្សំរបស់វាដើម្បីបញ្ជាក់គាំទ្រចំណុចនេះឡើយ ហើយក៏ពុំបានបង្ហាញអំពីរបៀបដែលបានធ្វើឲប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះដែរ។

103. ដូចគ្នាដែរ ពុំមានចំណុចអះអាងណាមួយត្រូវបានបញ្ជាក់ ដូចដែល សហចៅក្រមស៊ើបអង្កេតបានលើកឡើងថាការដោះលែងលោក **កាំង ហ្គេកអ៊ាវ** "...... *អាចនឹងបង្កឲមានការសំដែងនូវការមិនពេញចិត្តជាទូទៅ ដែលអាចបង្កឲមានអំពើហិង្សា*"។

104. មេធាវីការពារក្តីបានសួរខ្លួនឯងថា តើមានពត៌មានណាខ្លះ ដែលសហចៅក្រមស៊ើបអង្កេតបានលើកយកមកធ្វើជាមូលដ្ឋានដើម្បីវាយតំលៃថាអាចបង្កឲមានអំពើហិង្សានោះ។ យើងអាចអះអាងបានដូចគ្នាដែរថា ការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ**នេះដែលបានរំលោភលើច្បាប់ជាតិ និងអន្តរជាតិអាចជាកត្តាចំបងមួយដែលបង្កើតឲមានអំពើហិង្សា ឬយ៉ាងហោចណាស់ឲមានចលាចលនៃគំនិតដែរ។

105. ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងពេលសវនាអំពីការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ថាលោក **កាំង ហ្គេកអ៊ាវ** មានសេរីភាពតាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៩ នៅពេលនោះគាត់ពុំដែលបានបង្កអ្វីដែលនាំឲប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ។ នេះជាចំណុចតែមួយគត់នៅក្នុងសំណុំរឿង ដែលផ្តល់ជាគំនិតអំពីប្រតិកម្មរបស់សាធារណជន ក្នុងករណីមានការដោះលែងលោក **កាំង ហ្គេកអ៊ាវ**។

106. គួរកត់សំគាល់ថា ជាឧទាហរណ៍ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់យូហ្គូស្លាវី ជនដែលត្រូវចោទពីបទឧក្រិដ្ឋកម្មសង្រ្គាមត្រូវបានដោះលែងឲមានសេរីភាព ក្នុងអំឡុងពេលរង់ចាំការជំនុំជម្រះពេលនោះវាពុំបានបង្កឲប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ បន្ទាប់ពីចៅក្រមបានចេញសេចក្តីសំរេចនោះ ហើយម្យ៉ាងទៀត អង្គហេតុដែលបានចោទប្រកាន់នោះទើបតែកើតឡើងបានប៉ុន្មានឆ្នាំតែប៉ុណ្ណោះ[44]។

---

[43] ដូចគ្នា។

[44] ជាឧទាហរណ៍ សូមមើលរឿងក្តីរបស់លោក រ៉ាមូស ហារ៉ាឌីណា(Ramush Haradinaj)ខាងលើនេះ។

107. ដូច្នេះ មេធាវីការពារក្ដីសូមអះអាងថា ការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈជាមូលហេតុមួយ មិនគ្រប់គ្រាន់ និងមិនសមហេតុផលដើម្បីអះអាងអំពីការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ**នោះឡើយ។

108. ក្នុងកាលៈទេសៈដែលអង្គបុរេជំនុំជម្រះយល់ថា មូលហេតុនោះសមហេតុផល យើងគួរកត់សំគាល់ថា តុលាការអឺរ៉ុបយល់ឃើញថា ប្រសិនបើស្ថានភាពតំរូវនៃសណ្ដាប់ធ្នាប់សាធារណៈ ជាកត្តាមួយ សមហេតុផលដើម្បីឃុំខ្លួនអ្នកប្ដឹងសុំនោះ កត្តានោះនឹងត្រូវបានកាត់បន្ថយទៅតាមពេលវេលា[45] ។

109. មេធាវីការពារក្ដីសូមអះអាងថា ដូច្នេះ ប្រសិនបើមូលហេតុនោះសមហេតុផលកាលពីឆ្នាំ១៩៩៩ តែ សំរាប់រយៈពេល៨ឆ្នាំក្រោយពីការចាប់ខ្លួនលោក **កាំង ហ្គេកអ៊ាវ** និងរយៈពេល៣០ឆ្នាំក្រោយពី អង្គហេតុនោះបានកើតឡើង វាលែងក្លាយជាមូលហេតុសមហេតុផលទៀតឡើយ។

២ <u>ការការពារសន្តិសុខផ្ទាល់ខ្លួនអោយលោក **កាំង ហ្គេកអ៊ាវ**</u>

**110.** សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា៖ *មិនមែនជាការហួសហេតុពេកទេដែលអះអាងថា នៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជននេះអាច(.....) ប៉ះពាល់ដល់សន្តិសុខផ្ទាល់របស់ជននេះ[46] ។*

111. ជាថ្មីម្ដងទៀត ក្នុងសេចក្ដីសំរេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតពុំបានបញ្ជាក់អំពីចំណុចដែល អះអាងថា ការដោះលែងលោក **កាំង ហ្គេកអ៊ាវ**ឲមានសេរីភាពនេះ អាចបណ្ដាលឲរូបគាត់មាន គ្រោះថ្នាក់ផ្សេងៗនោះឡើយ។

112. ដោយឡែក មេធាវីការពារក្ដីសូមរំលឹកជូនអង្គបុរេជំនុំជម្រះថា ដូចដែលបង្ហាញពីខាងលើនេះ តាំងពី ឆ្នាំ១៩៧៩ រហូតដល់ខែឧសភា ឆ្នាំ១៩៩៩ លោក **កាំង ហ្គេកអ៊ាវ** ពុំដែលជាធ្លាប់រងគ្រោះពីការវាយ ប្រហារណាមួយដែលនាំឲប៉ះពាល់ដល់សន្តិសុខផ្ទាល់ខ្លួនគាត់ ដូចដែលបានចោទប្រកាន់លើគាត់នៅ ពេលនេះឡើយ។

113. ដូចគ្នានឹងជនសង្ស័យដ៏ទៃទៀតដែរ ដែលឈ្មោះរបស់ពួកគេត្រូវបានផ្សព្វផ្សាយ តាមអត្ថបទ សារពត៌មាន បើទោះជាបច្ចុប្បន្ននេះ ពួកគេកំពុងរស់នៅយ៉ាងមានសេរីភាពក៏ដោយ ក៏ពួកគេពុំបាន ទទួលនូវការគំរាមកំហែងផ្នែកសន្តិសុខនោះដែរ។

---

[45] សូមមើលរឿងក្ដីប៊ែកណា តទល់នឹងបារាំង ថ្ងៃទី២៦ ធ្នូ ២០០៦ វាក្យខ័ណ្ឌ៤៦។

[46] សូមមើលវាក្យខ័ណ្ឌ ២២នៃដីកាសំរេចរបស់សហចៅក្រមស៊ើបអង្កេត។

114. សហចៅក្រមស៊ើបអង្កេតពុំបានបង្ហាញអំពីគ្រោះថ្នាក់ជាក់ស្ដែងពីការវាយប្រហារណាមួយ ទៅលើសន្ដិសុខ របស់លោក **កាំង ហ្គេកអ៊ាវ**ឡើយ។ ដូច្នេះ លោក **កាំង ហ្គេកអ៊ាវ**មិនអាចត្រូវបានឃុំខ្លួនដោយសារមូលហេតុនេះទេ។

115. ដោយឡែក មេធាវីការពារក្ដីសូមលើកឡើងថា ប្រសិនបើចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាភ័យខ្លាច អំពីសន្ដិសុខរបស់លោក **កាំង ហ្គេកអ៊ាវ** និងចង់ការពារគាត់ សហចៅក្រមអាចចាត់វិធានការណ៍ផ្សេងទៀត ដែលអាចធ្វើឱគាត់មានសេរីភាពផង និងអាចការពារពីការវាយប្រហារផ្សេងទៀតលើរូបគាត់ផងដែរ ដូចជាការកំណត់និវេសណដ្ឋានឱគាត់ជាដើម។

៣ <u>ការធានាអំពីវត្តមានរបស់លោក **កាំង ហ្គេកអ៊ាវ** ក្នុងដំណើរការនីតិវិធី</u>

116. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថាការឃុំខ្លួនលោក **កាំង ហ្គេកអ៊ាវ** ជាបណ្ដោះអាសន្នគឺជាការសំខាន់ "ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការនីតិវិធី"[47]។

117. ដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា "ទោសឧក្រិដ្ឋមួយជីវិតដែលលោក ឌុច ត្រូវប្រឈមនាំឱមានការបារម្ភថាគាត់អាចស្វែងរកការរត់គេចខ្លួនពីដំណើរការរបស់តុលាការ"[48]។

118. ជាថ្មីម្ដងទៀត ពុំមានចំណុចណាមួយដែលអះអាងអំពីមូលហេតុនេះឡើយ។ អំណះអំណាងតែមួយគត់ដែលចៅក្រមបានលើកឡើងគឺការដែលលោក **កាំង ហ្គេកអ៊ាវ**អាចប្រឈមមុខនឹងទោសឧក្រិដ្ឋមួយជីវិត ។

119. មេធាវីការពារក្ដីសូមរំលឹកឡើងវិញអំពីជំហរដ៏នឹងនររបស់តុលាការអឺរ៉ុបលើចំណុចនេះ មួយផ្នែក គឺថា"*ត្រូវបង្ហាញពីភាពជាក់ស្ដែងនៃគ្រោះថ្នាក់នៃការរត់គេចនេះ*"[49] មួយផ្នែកទៀតគឺ "*ភាពជាក់ស្ដែងនៃគ្រោះថ្នាក់នៃការរត់គេចនេះ ត្រូវបានកាត់បន្ថយជាមួយពេលវេលា*" ហើយជាចុងក្រោយគឺ "*គ្រោះថ្នាក់នៃការរត់គេចនេះមិនអាចត្រូវបានវាយតំលៃ ដោយគ្រាន់តែផ្អែកលើកំរិតធ្ងន់ធ្ងរនៃទោសទណ្ឌនោះឡើយ*"[50]។

120. ដោយឡែក មេធាវីការពារក្ដីសូមលើកឡើងថាចៅក្រមត្រូវពិចារណាលើចំណុចដូចខាងក្រោមនេះ៖

---

[47] សូមមើលវាក្យខ័ណ្ឌ ២៣នៃដីកាសំរេចរបស់សហចៅក្រម។

[48] សូមមើលវាក្យខ័ណ្ឌ ២២នៃដីកាសំរេចរបស់សហចៅក្រម។

[49] សូមមើលរឿងក្ដីមូលេ(Muller) តទល់នឹងបារាំង ថ្ងៃទី១៨ កុម្ភៈ ១៩៩៧ វាក្យខ័ណ្ឌ៤២ ។

[50] សូមមើលរឿងក្ដីប៊ែកណា តទល់នឹងបារាំង ថ្ងៃទី២៦ ធ្នូ ២០០៦ វាក្យខ័ណ្ឌ៤៥ ។

- លោក **កាំង ហ្គេកអ៊ាវ**បានបន្តរស់នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៩មក
- គាត់ពុំបានជំទាស់ទៅនឹងការចាប់ខ្លួនគាត់កាលពីខែឧសភា ឆ្នាំ១៩៩៩ឡើយ
- គាត់ពុំដែលបដិសេធថាខ្លួនពុំមែនជាប្រធានមន្ទីរស-២១ឡើយ
- គាត់បានប្រកាសថា ខ្លួនបានត្រៀមខ្លួនរួចជាស្រេចក្នុងការបកអាក្រាត អំពីបទឧក្រិដ្ឋដែលពួកខ្មែរក្រហមបានប្រព្រឹត្ត

121. ដោយឡែក គាត់ក៏បាននិយាយដែរថា គាត់បានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលការកាត់ទោស ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

122. ចំណុចទាំងអស់នេះបង្ហាញថា ប្រសិនបើលោក **កាំង ហ្គេកអ៊ាវ** ត្រូវបានដោះលែង គាត់នឹងមិនរត់គេចពីការកាត់ក្តីឡើយ។

123. មិនតែប៉ុណ្ណោះ លោក **កាំង ហ្គេកអ៊ាវ**អាចផ្តល់នូវការធានាគ្រប់គ្រាន់ដូចជា៖

- លោក **កាំង ហ្គេកអ៊ាវ** មានកូន៤នាក់ និងចៅ ដែលទាំងអស់គ្នាកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលតែងតែទាក់ទងមកគាត់ជាប្រចាំ។

- លោក **កាំង ហ្គេកអ៊ាវ** ពុំមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដែលអាចធ្វើឱគាត់រត់ចេញពីប្រទេសកម្ពុជាបានឡើយ។

- លោក **ការ សាវុត្ថ** ដែលជាមេធាវីរបស់លោក **កាំង ហ្គេកអ៊ាវ** យល់ព្រមធានាអំពីវត្តមានរបស់គាត់ក្នុងដំណើរការនីតិវិធី។

## ខ លោក កាំង ហ្គេកអ៊ាវត្រូវទទួលបានដោះលែងឱមានសេរីភាព ហើយប្រសិនបើចាំបាច់អាចដាក់គាត់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន

124. យោងលើធាតុផ្សំទាំងឡាយ ដែលបានបង្ហាញជូនខាងលើនេះ មេធាវីការពារក្តីសូមឱអង្គបុរេជំនុំជម្រះបដិសេធដីកាសំរេចឱឃុំខ្លួនជាបណ្តោះអាសន្នចុះថ្ងៃទី៣១ កក្កដា ២០០៧ និងដោះលែងលោក **កាំង ហ្គេកអ៊ាវ** ឱមានសេរីភាព ហើយប្រសិនបើចាំបាច់អាចដាក់គាត់ អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។

125. មេធាវីការពារក្តីសំណូមពរឱចៅក្រមចាត់វិធានការណ៍ផ្សេងក្រៅអំពីការឃុំខ្លួន។

126. ជាពិសេស អង្គបុរេជំនុះជម្រះអាចសំរេចធ្វើការកំណត់និវេសណដ្ឋានឲលោក **កាំង ហ្កេកអ៊ាវ** ដែលជាប្រយោជន៏ម្យ៉ាង ដោយអាចឲដាក់រូបគាត់ឲនៅឆ្ងាយពីជនដ៏ទៃទៀតដែលអាចត្រូវបានចាប់ខ្លួននិងចោទប្រកាន់ ហើយដែលជនទាំងនោះអាចមានវិវាទផលប្រយោជន៏ជាមួយគាត់។

## គ <u>ទោះជាក្នុងករណីណាក៏ដោយ មេធាវីការពារក្តីសូមឲមានការជួសជុលព្យសនកម្មដែលលោក កាំង ហ្កេកអ៊ាវ បានទទួលអំពីការឃុំខ្លួនបណ្តោះអាសន្នដែលហួសពីការកំណត់របស់ច្បាប់នេះ</u>

127. មេធាវីការពារក្តីសូមឲអង្គបុរេជំនុះជម្រះសំរេចសេចក្តីផងដែរអំពី៖

- ក្នុងករណីសំរេចឲរួចខ្លួន ត្រូវមានការជួសជុលជាសំណងហិរញ្ញវត្ថុដល់លោក **កាំង ហ្កេកអ៊ាវ** មួយផ្នែកអំពីការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលជាង៨ឆ្នាំកន្លងមកនេះ និងមួយផ្នែកទៀត អំពីព្យសនកម្មដែលគាត់ទទួលរង ពីការរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលសមស្រប ឬដោះលែង។
- ក្នុងករណីសំរេចផ្តន្ទាទោស មួយផ្នែក រយៈពេលជាង៨ឆ្នាំដែលបានឃុំខ្លួនគាត់កន្លងមកនេះនឹងត្រូវបានគិតបញ្ចូលលើថិរវេលានៃទោសដែលគាត់ត្រូវទទួល និងមួយផ្នែកទៀត ចំពោះព្យសនកម្មដែលគាត់ទទួលរងពីការរំលោភបំពានលើសិទ្ធិរបស់គាត់ ក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលសមស្រប ឬដោះលែង ត្រូវកាត់បន្ថយពីលើទោសទណ្ឌដ៏ទៃទៀតដែលគាត់ត្រូវទទួលរង ។

128. តុលាការឧទ្ធរណ៏នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរវ៉ាន់ដា បានចេញសាលដីកាមួយកាលពីថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ក្នុងរឿងក្តីបារ៉ាយ៉ាហ្គីហ្សាដែលបង្ហាញនូវការគាំទ្រនូវសំណូមពររបស់មេធាវីការពារក្តី។

129. ក្នុងរឿងក្តីនេះ តុលាការឧទ្ធរណ៏បានសំរេចថា សិទ្ធិរបស់លោកបារ៉ាយ៉ាហ្គីហ្សាត្រូវបានរំលោភបំពានហើយជាវិបាក គាត់ត្រូវទទួលបាននូវការជួសជុលព្យសនកម្មដូចខាងក្រោមនេះ៖

“......សម្រេចថាចំពោះការរំលោភលើសិទ្ធិរបស់គាត់ អ្នកប្តឹងឧទ្ធរណ៏មានសិទ្ធិទទួលបាននូវការជួសជុលសំណងដែលត្រូវកំណត់នៅកាលបរិច្ឆេទចេញសាលក្រមនៅសាលាដំបូង ដូចខាងក្រោម:

ក) ប្រសិនបើអ្នកប្តឹងឧទ្ធរណ៏ពុំមានពិរុទ្ធភាព គាត់ត្រូវទទួលសំណងហិរញ្ញវត្ថុ

ខ) ប្រសិនបើអ្នកប្ដឹងឧទ្ធរណ៍មានពិរុទ្ធភាព ទោសរបស់គាត់ត្រូវកាត់បន្ថយ ដោយពិចារណាលើការរំលោភសិទ្ធិរបស់គាត់[51]”។

130. នៅក្នុងសាលដីកាចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៣ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វាន់ដាបានដាក់ឲអនុវត្តនូវសេចក្ដីសំរេចខាងលើនេះ ដូចដែលបង្ហាញជូនជាបន្តបន្ទាប់ទៅនេះ។

131. បន្ទាប់ពីបានឃើញថា ទោសទណ្ឌដែលសមរម្យបំផុតដើម្បីផ្ដន្ទាទោសលើលោក បារ៉ាយ៉ាហ្គីហ្សា គឺបទឧក្រិដ្ឋមួយជីវិត ជាដំបូង អង្គជំនុំជម្រះបានយល់ថាមានការរំលោភបំពានលើសិទ្ធិរបស់គាត់ ដូច្នេះសំរេចបន្ថយទោសគាត់ឲនៅត្រឹមដាក់ពន្ធនាគារចំនួន៣៥ឆ្នាំ ហើយជាបន្ទាប់មកទៀត គេបានគិតបញ្ចូលលើថិរវេលាដែលបានឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន។

132. ជាបញ្ចប់ លោក បារ៉ាយ៉ាហ្គីហ្សា ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន២៧ឆ្នាំ ៣ខែ និង២១ថ្ងៃ[52]។

133. ដូច្នេះ មេធាវីការពារក្ដីសំណូមពរថា ប្រសិនបើលោក **កាំង ហ្កេកអ៊ាវ** ត្រូវបានផ្ដន្ទាទោស ក្រៅពីការគិតបញ្ចូលលើថិរវេលាសរុបនៃការឃុំខ្លួនជាបណ្ដោះអាសន្នកន្លងមកពីទោសដែលបានប្រកាសដោយយោងតាមមាត្រា ៥០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី[53] និងយុត្តិសាស្ត្ររបស់អន្តរជាតិទាក់ទងនឹងបញ្ហានេះ[54] ដូច្នេះការរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលសមស្រប ឬដោះលែង ផ្ដល់ឲគាត់នូវសិទ្ធិទទួលបានការជួសជុលព្យសនកម្ម ដែលមានន័យថាជាការបន្ថយលើទោសដែលគាត់ត្រូវទទួលជាច្រើនឆ្នាំ។

---

[51] សូមមើលរឿងក្ដីព្រះរាជអាជ្ញា តទល់នឹងបារ៉ាយ៉ាហ្គីហ្សា TPIR តុលាការឧទ្ធរណ៍ សាលដីកា (សុំឲព្រះរាជអាជ្ញាពិនិត្យឡើងវិញ) ថ្ងៃទី៣១ មិនា ២០០៣ វាក្យខ័ណ្ឌ៧៤ និង៧៥ ។

[52] សូមមើលរឿងក្ដីព្រះរាជអាជ្ញា តទល់នឹងបារ៉ាយ៉ាហ្គីហ្សា TPIR អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងទោស ថ្ងៃទី៣ ធ្នូ ២០០៣ វាក្យខ័ណ្ឌ១១០៦ និង១១០៧។

[53] មាត្រា ៥០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី (ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន)៖ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។

[54] សូមមើល ជាឧទាហរណ៍ រឿងក្ដីព្រះរាជអាជ្ញា តទល់នឹងTadic ICTY AC ថ្ងៃទី២០ មករា ២០០៦ វាក្យខ័ណ្ឌ៣៨៖ ...សាលាឧទ្ធរណ៍ទទួលស្គាល់ថានីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកប្ដឹងឧទ្ធរណ៍នៅសហពន្ធ័អាឡឺម៉ង់ មានដើមកំណើតជាសំខាន់ពីនីតិវិធីព្រហ្មទណ្ឌតែមួយ ដែលពេលនេះគាត់កំពុងត្រូវបានកាត់ទោសនៅតុលាការអន្តរជាតិ។ ដូច្នេះ យុត្តិធម៌ទាមទារឲគិតបញ្ចូលនូវរយៈពេលដែលអ្នកប្ដឹងឧទ្ធរណ៍នោះត្រូវបានឃុំខ្លួននៅសហពន្ធ័អាឡឺម៉ង់ នៅមុនពេលដែលតុលាការបានធ្វើបណ្ដឹងសុំឲផ្ទេរជននោះពីសហព័ន្ធអាឡឺម៉ង់មក។

## ផ្អែកតាមហេតុផលទាំងនេះ

134. សំរេចថា សវនាការបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាសាធារណៈ ដោយអនុលោមទៅតាមមាត្រា ៧៧(៦) នៃ វិធានផ្ទៃក្នុង។

យល់ស្របតាមបណ្ដឹងឧទ្ធរណ៍របស់លោក **កាំង ហ្គេកអ៊ាវ** និងកែប្រែលើដីកាសំរេចដែលបានប្ដឹងឧទ្ធរណ៍.

<u>**ជាមធ្យោបាយទី១**</u>

**សំរេច និងកាត់ក្ដីថា** សិទ្ធិរបស់ លោក **កាំង ហ្គេកអ៊ាវ** ក្នុងការទទួលបាននូវជំនុះជម្រះក្នុងរយៈពេលមួយសមស្រប ឬដោះលែងត្រូវបានរំលោភបំពាន ហើយថាការឃុំខ្លួនគាត់អស់ចិរវេលាជាង៨ឆ្នាំនេះ បន្ថែមជាឆ្នាំទី៩ទៀតដោយសហចៅក្រមស៊ើបអង្កេត គឺផ្ទុយនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិផ្នែកការពារសិទ្ធិមនុស្ស

<u>**ជាមធ្យោបាយទី២**</u>

**សំរេច និងកាត់ក្ដីថា** ល័ក្ខខ័ណ្ឌក្នុងដីកាសំរេចឃុំខ្លួនជាបណ្ដោះអាសន្នចុះថ្ងៃទី៣១ កក្កដា ២០០៧ មិនត្រូវបានបំពេញ

<u>**ជាវិបាក**</u>

**បង្គាប់**ឱដោះលែងលោក **កាំង ហ្គេកអ៊ាវ** ឱមានសេរីភាពជាបន្ទាន់

**ដាក់**លោក **កាំង ហ្គេកអ៊ាវ** អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយធ្វើការកំណត់និវេសណដ្ឋានឱគាត់បាន ក្នុងករណីចាំបាច់

<u>**ទោះជាក្នុងករណីណាក៏ដោយ**</u>

**សំរេច និងកាត់ក្ដីថា** ការរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬដោះលែង ក្នុងដំណាក់កាលនៃនីតិវិធីធ្វើឱលោក **កាំង ហ្គេកអ៊ាវ**មានសិទ្ធិទទួលបាននូវការជួសជុលសំណង ដែលត្រូវកំណត់នៅកាលបរិច្ឆេទចេញសាលក្រមនៅសាលាដំបូង តាមរបៀបដូចខាងក្រោមនេះ៖

ក ក្នុងករណីសំរេចឱលោក **កាំង ហ្គេកអ៊ាវ**ពុំមានពិរុទ្ធភាព គាត់ត្រូវទទួលសំណងហិរញ្ញវត្ថុ

ខ	ក្នុងករណីក្នុងករណីសំរេចឲលោក **កាំង ហ្គេកអ៊ាវ**មានពិរុទ្ធភាព មួយផ្នែក រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលលើទោសដែលបានប្រកាស និងមួយផ្នែកទៀត ទោសរបស់គាត់នឹងត្រូវបានកាត់បន្ថយ ដោយយោងលើការរំលោភលើសិទ្ធិរបស់គាត់ ។

| | | | |
|---|---|---|---|
| ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ | ភ្នំពេញ | មេធាវី **ការ សាវុត្ថ**<br><br>មេធាវី Francois Roux | |
| កាលបរិច្ឆេទ | ទីកន្លែង | ឈ្មោះ | ហត្ថលេខា |